**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យ លេខ ៩៩ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតធនាគារ-អភិវឌ្ឍន៍ជនបទ

-បានឃើញអនុក្រឹត្យលេខ ៩៩ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ

-តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## សម្រេច

**មាត្រា ១** : មាត្រា ៣ ថ្មី នៃអនុក្រឹត្យលេខ ៩៩ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ ត្រូវបានកែសម្រួលដូចខាងក្រោម :

មាត្រា ៣ ថ្មី : ភារកិច្ចចំបងរបស់ធនាគារអភិវឌ្ឍន៍ជនបទរួមមាន :

១- ផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ដែលមានសកម្មភាពទ្រទ្រង់សេដ្ឋកិច្ចជនបទ ។

២- ចរចារជាមួយដៃគូអភិវឌ្ឍន៍នានាដើម្បីទាក់ទាញហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទានសំរាប់ពង្រីកសកម្មភាពរបស់ធនាគារ ។

៣- សហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុនានា ក្នុងការផ្តល់ឥណទានដើម្បីអនុវត្តគម្រោងក្នុងវិស័យកសិកម្ម អភិវឌ្ឍន៍ជនបទ និងសេដ្ឋកិច្ចជនបទ ។

៤- ជំរុញការបណ្តុះបណ្តាលផ្នែកជំនាញដល់បុគ្គលិកប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ។

៥- អាចអនុវត្តគម្រោងឥណទានតាមសំណើរបស់ដៃគូអភិវឌ្ឍន៍ ក្នុងកាលៈទេសៈដែលប្រតិបត្តិករមីក្រូហិរញ្ញវត្ថុពុំអាចអនុវត្តបាន ។

មាត្រា ១៣ ថ្មី: ធនាគារអភិវឌ្ឍន៍ជនបទ អាចផ្តល់ឥណទានដើម្បីអនុវត្តគំរោងអភិវឌ្ឍន៍ពិសេសណាមួយរបស់រាជរដ្ឋាភិបាល ឬ គំរោងពិសេសផ្សេងៗទៀត ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្ត-ក្រុង មានភារកិច្ចអនុវត្តនូវអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល**

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ៣*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*